Australian Government

Job Services Australia
people • skills • jobs

# Work Experience: Drought Force

កងកម្លាំងសម្រាប់គ្រោះរាំងស្ងួត (Drought Force) អាចជួយលោកអ្នកឲ្យទទួលបានជំនាញ និងបទពិសោធន៍ការងារ តាមរយៈការផ្តល់ជំនួយដល់កសិដ្ឋាន និងសហគមន៍កសិកម្មនីមួយៗដែលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីគ្រោះរាំងស្ងួត។

Drought Force ផ្តល់ជំនួយដល់អចលនទ្រព្យកសិដ្ឋាន និងជួយទប់ស្កាត់ការផ្លាស់ចេញពីតំបន់នូវកម្លាំងពលកម្មតាមកសិដ្ឋាន។

សកម្មភាព Drought Force មាន ៖

- ជួយកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត
- សម្រាលបន្ទុកកសិករ និងគ្រួសាររបស់គេដែលរងគ្រោះភាពរាំងស្ងួត
- ធ្វើឲ្យប្រាកដថា កសិដ្ឋាន និងអចលនទ្រព្យ មានភាពគង់វង្ស ហើយអាចទប់ទល់នឹងគ្រោះរាំងស្ងួត នៅពេលមានគ្រោះរាំងស្ងួត។
- លើកទឹកចិត្តប្រជាជនឲ្យបិតនៅក្នុងសហគមន៍តាមតំបន់របស់ខ្លួនតទៅទៀត ដោយការរក្សា និង កសាងជំនាញតាមតំបន់។
- ទ្រទ្រង់សេដ្ឋកិច្ចមូលដ្ឋាន ដើម្បីដោះស្រាយផលប៉ះពាល់ពីគ្រោះរាំងស្ងួត។
- ទ្រទ្រង់ការងើបងើរជាអាទិភាពរបស់សហគមន៍តាមតំបន់។

ការចូលរួមសកម្មភាព Drought Force អាចនឹងធ្វើឡើងជាក្រុម ដោយធ្វើការងារក្នុងលក្ខណៈជាក្រុមជាមួយនឹងអ្នកស្វែងរកការងារធ្វើផ្សេងៗទៀត ឬធ្វើការងារដោយឡែកៗខ្លួន ជាមួយកសិករផ្តល់ការងារ។

អ្នកចូលរួមក្នុងសកម្មភាព Drought Force ទាំងអស់ត្រូវទទួលការបណ្តុះបណ្តាលហ្វឹកហ្វឺនដែលមានការរៀបចំ ទៅតាមកាលៈទេសៈ និងបើអាចធ្វើបាន។ ការបណ្តុះបណ្តាលហ្វឹកហ្វឺននេះ អាចរួមមានទាំងការបណ្តុះបណ្តាលហ្វឹកហ្វឺនដែលមាន និងគ្មានការទទួលស្គាល់ជាផ្លូវការ។

អ្នកស្វែងរកការងារធ្វើក៏អាចចូលរួមផងដែរ នៅអំឡុងពេលដែលមិនរំខានប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចផ្សេងៗរបស់ខ្លួន ដូចជាការសិក្សា ការងារមិនពេញម៉ោង ឬមិនទៀងទាត់ ឬបន្ទុកចិញ្ចឹមបីបាច់កូន។

## ទីកន្លែងនៃសកម្មភាព Drought Force

សកម្មភាព Drought Force អាចអនុវត្តបាន តែនៅតំបន់ដែលរដ្ឋាភិបាលអូស្ត្រាលីប្រកាសថាជាតំបន់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ (Australian Government as Exceptional Circumstance) (EC) ប៉ុណ្ណោះ។

ដើម្បីកំណត់ថាតើតំបន់ណាមួយត្រូវបានប្រកាសថាជាតំបន់ EC ឬជាតំបន់មានសិទ្ធិទទួលវិធានការជំនួយគ្រោះរាំងស្ងួតផ្សេងទៀតពីរដ្ឋាភិបាលអូស្ត្រាលី ឬយ៉ាងណានោះ សូមបើកមើលគេហទំព័ររបស់ក្រសួងកសិកម្ម នេសាទ និងរុក្ខាប្រមាញ់ (Department of Argriculture Fisheries and Forestry): **daff.gov.au**។

## Drought Force 60+

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលសម្រេចចិត្តចូលរួមក្នុង Drought Force រយៈពេល ៦០ម៉ោង ឬច្រើនជាងនេះក្នុងរវាងពេល ៦អាទិត្យនោះ  លោកអ្នកនឹងមិនចាំបាច់ស្វែងរកការងារធ្វើទេ ពីព្រោះលោកអ្នកត្រូវបានចាត់ទុកថាបានរួមចំណែកយ៉ាងខ្លាំងលើវិស័យកសិកម្មតាមតំបន់ដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត។ ទោះជាយ៉ាងណាលោកអ្នកនៅតែត្រូវជួបជាមួយស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia) របស់លោកអ្នកជាទៀតទាត់ដែរ។

## សម្រាប់ Drought Force ប៉ុណ្ណោះ

ប្រជាជនដែលមានអាយុលើសពី ២០ឆ្នាំ ហើយគ្មានសិទ្ធិទទួលជំនួយទ្រទ្រង់ប្រាក់ចំណូល អាចស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាព Drought Force បាន។ លោកអ្នកអាចទាក់ទងជាមួយស្ថាប័នផ្តល់ Job Services Australia ដោយផ្ទាល់ ដើម្បីសុំចូលរួមសកម្មភាព Drought Force។

## តើអ្នកណាអាចចូលរួមបាន?

ប្រសិនបើលោកអ្នកជាអ្នកស្វែងរការងារធ្វើដែលបានចុះឈ្មោះជាមួយស្ថាប័ន Job Services Australia លោកអ្នកអាចស្ម័គ្រចិត្តចូលរួមក្នុង Drought Force ពេលណាក៏បាន ក្នុងករណីដែលលោកអ្នក និងស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នកយល់ឃើញថាការស្ម័គ្រចិត្តនេះមានប្រយោជន៍ចំពោះ លោកអ្នក។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើ ដែលមានតម្រូវការបទពិសោធន៍ការងារ (Work Experience Activity Requirement) លោកអ្នកអាចបំពេញតម្រូវការបែបនេះបាន ដោយការចូលរួមសកម្មភាពជាមួយកម្លាំងសម្រាប់គ្រោះរាំងស្ងួត។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលត្រូវបំពេញសកម្មភាពសកម្មខ្លាំងក្លា (Intensive Activity) លោកអ្នកអាចបំពេញតម្រូវការនេះតាមរយៈការចូលរួមជាមួយ Drought Force។ ស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នកនឹងផ្តល់ការណែនាំដល់លោកអ្នក ថាតើលោកអ្នកត្រូវបំពេញ Intensive Activity ឬយ៉ាងណា។

ការចូលរួមសកម្មភាព Drought Force គឺអាចធ្វើទៅបានតាមរយៈការស្ម័គ្រចិត្តពីសំណាក់អ្នកស្វែងរកការងារធ្វើតែប៉ុណ្ណោះ។ ប្រសិនបើលោកអ្នកមិនចង់ចូលរួមសកម្មភាព Drought Force ទេ គេអាចចាត់លោកអ្នកឱ្យចូលរួម Work Experience Activity ផ្សេងទៀតដែលសមរម្យ ដើម្បីបំពេញតាមតម្រូវការចូលរួមរបស់លោកអ្នក ទៅតាមកាលៈទេសៈសមស្រប។

8FS09446JSA/khmer

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលទទួលជំនួយទ្រទ្រង់ប្រាក់ចំណូល ហើយចូលរួមសកម្មភាពជាមួយ Drought Force លោកអ្នកនឹងមានសិទ្ធិទទួលប្រាក់បន្ថែម $20.80 សម្រាប់រយៈពេល២សប្តាហ៍ម្តង ដើម្បីសម្រាលបន្ទុកថ្លៃចូលរួម។

ប្រសិនបើលោកអ្នកគ្រាន់តែជាអ្នកចូលរួម Drought Force លោកអ្នកនឹងមិនមានសិទ្ធិទទួល ប្រាក់បន្ថែមនេះទេ។

## របៀបដាក់ពាក្យសុំ

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើ ឬអ្នកស្ម័គ្រចិត្តដែលមានចំណាប់អារម្មណ៍ចំពោះការចូលរួមក្នុង Drought Force លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់ Job Services Australia របស់លោកអ។

## ភារកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart , ប្រាក់ឧបត្ថម្ភយុវជន (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ដោយមានការតម្រូវឲ្យចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារ ហើយចូលរួមក្នុងសកម្មភាព ដែលនឹងជួយឱ្យលោកអ្នកបានទទួលការងារធ្វើ។

ស្ថាប័នផ្តល់ Job Services Australia នឹងពិចារណាអំពីស្ថានភាពរបស់លោកអ្នកផ្ទាល់ ហើយចរចាអំពីសកម្មភាពសមរម្យ ដើម្បីដាក់បញ្ចូលក្នុងផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនេះបានទេ លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់សេវារបស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តសកម្មភាពដែលបានព្រមព្រៀងនោះ ការខកខាននេះអាចប៉ះពាល់ដល់ប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូលរបស់លោកអ្នក។

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

## ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

### ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

### ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

## សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**